# ***សារស្វាគមន៍***

អង្គភាពគ្រប់គ្រងហានិភ័យត្រូវបង្កើតឡើងនៅអគ្គនាយកដ្ឋានត្រួតពិនិត្យទំនិញនីហរ័ណ-អាហរ័ណ និងបង្ក្រាបការក្លែងបន្លំ ( ***កាំកុងត្រូល***) នៃក្រសួងពាណិជ្ជកម្មកម្ពុជា ក្រោមប្រកាសលេខ ១៥៥- អឹមអូស៊ី /អេស អឹម ២០១០ ចុះថ្ងៃទី ១៣ ខែ កញ្ញា ២០១០។ អនុលោមតាមអនុក្រឹត្យលេខ ២១ អ.ន.ក្រ ចុះថ្ងៃទី ១ ខែ មិនា ឆ្នាំ ២០០៦ ស្តីពីកិច្ចសម្រួលពាណិជ្ជកម្មតាមរយៈការគ្រប់គ្រងហានិភ័យ អង្គភាពខាងលើមានតួនាទីណែនាំ និងសម្របសម្រួលការអនុវត្តអភិក្រមផ្អែកលើហានិភ័យទៅក្នុងគ្រប់សកម្មភាពទាំងអស់របស់អគ្គនាយកដ្ឋានកាំកុងត្រូល។

អង្គភាពនេះនឹងអនុវត្តការងាររបស់ខ្លួនក្រោមក្របខណ្ឌផែនការយុទ្ធសាស្ត្រគ្រប់គ្រងហានិភ័យរបស់អគ្គនាយកដ្ឋានកាំកុងត្រូល ដែលតំរូវអោយមានការរៀបចំសៀវភៅណែនាំស្តីពីនិតិវិធីក្នុងការអនុវត្តន៍អភិក្រម។ សៀវភៅណែនាំនេះ មានគោលបំណងកំណត់មាគ៌ាសំរាប់អង្គភាពនៅពេលដែលខ្លួនអនុវត្តអាណត្តិរបស់ខ្លួន។

ម្យ៉ាងវិញទៀត អង្គភាពនឹងធ្វើការងាររបស់ខ្លួនជាប្រព័ន្ធ តាមរយៈទំនិញ ឬសកម្មភាពដែលអគ្គនាយកដ្ឋានកាំកុងត្រូលទទួលខុសត្រូវ ដើម្បីធានាថា ក្នុងរយៈពេលដ៏សមស្របមួយ អភិក្រមផ្អែកមូលដ្ឋានលើហានិភ័យនេះ អាចនឹងត្រូវបានអនុវត្តទូទាំងអគ្គនាយកដ្ឋានកាំកុងត្រូល។

ជាមួយនេះដែរ អង្គភាពក៏មានតួនាទីសំខាន់ក្នុងការពិនិត្យមើលការងាររបស់ខ្លួនអោយបានត្រឹមត្រូវ ស៊ីចង្វាក់គ្នា និងសមស្រប និងធ្វើយ៉ាងណាអោយដំណើរការអនុវត្តការងារផ្ទៃក្នុងមានតម្លាភាព ដើម្បីកសាងទំនុកចិត្តក្នុងការងារវិភាគ និងផ្តល់ប្រឹក្សាយ៉ាងពេញលេញរបស់ខ្លួន។ ដោយយោងលើកត្តាទាំងនេះ ខ្ញុំសូមស្នើអោយមានការបោះពុម្ពសៀវភៅណែនាំនេះ និងសូមស្វាគមន៍រាល់ការចូលរួមមតិណែនាំកែលំអរ បំពេញបន្ថែម ដើម្បីធ្វើអោយសៀវភៅនេះកាន់តែប្រសើរឡើង និងងាយស្រួលសំរាប់ការអនុវត្តន៍។

***សូមអរគុណ***

រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ ២០១១

***ប្រតិភូរាជរដ្ឋាភិបាល***

***ទទួលបន្ទុកជាអគ្គនាយកកាំកុងត្រូល***

***ម៉ក់ ពេជ្ររិទ្ធ***

# សៀវភៅណែនាំអំពីនិតិវិធីសំរាប់អង្គភាពគ្រប់គ្រងហានិភ័យ

## ១. អាណត្តិរបស់អង្គភាពគ្រប់គ្រងហានិភ័យ

យោងតាមប្រកាសលេខ ១៩៥- អឹម អូ ស៊ី /អេស អឹម ២០១០ ចុះថ្ងៃទី ១៣ ខែកញ្ញា ២០១០ អង្គភាពគ្រប់គ្រងហានិភ័យមាន តួនាទី និងការទទួលខុសត្រូវដូចខាងក្រោម:

- រៀបចំ និងអនុវត្តផែនការគ្រប់គ្រងហានិភ័យរបស់អគ្គនាយកដ្ឋានគាំកុងត្រូល
- កំណត់អត្តសញ្ញាណហានិភ័យលើកម្មវិធីសកម្មភាពនានារបស់សាខានិមួយៗ ដែលត្រូវត្រួតពិនិត្យ
- អនុវត្តការវិភាគហានិភ័យ (វាយតំលៃហានិភ័យ គ្រប់គ្រងហានិភ័យ និងផ្សព្វផ្សាយហានិភ័យ) ក្រោមអាណត្តិរបស់អគ្គនាយកដ្ឋានគាំកុងត្រូល ដោយប្រើប្រាស់បទពិសោធន៍ល្អៗរបស់អន្តរជាតិ និងពិចារណាលើកាតព្វកិច្ចអន្តរជាតិផ្សេងៗរបស់កម្ពុជា ត្រូវបំពេញ
- លើកសំណើវិធីសាស្ត្រលំអិតសំរាប់គ្រប់គ្រងហានិភ័យដែលត្រូវអន្តរាគមន៍តាមសកម្មភាពកម្មវិធី ដើម្បីដាក់អោយសាខាគាំកុងត្រូលទាំងអស់អនុវត្ត
- សហការណ៍ជាមួយអ្នកគ្រប់គ្រងកម្មវិធី (នាយកដ្ឋាន និងសាខា) រៀបចំសៀវភៅណែនាំនិតិវិធីស្តង់ដា សំរាប់កម្មវិធីនាំចេញ-ចូល ដោយផ្អែកលើការគ្រប់គ្រងហានិភ័យ
- ផ្តល់គោលការណ៍ណែនាំពាក់ព័ន្ធផ្សេងទៀតស្តីពីការអនុវត្តន៍អភិក្រមផ្អែកលើហានិភ័យដល់សាខាគាំកុងត្រូលទាំងអស់
- ធ្វើការផ្សព្វផ្សាយក្នុងអគ្គនាយកដ្ឋានគាំកុងត្រូល និងដល់ស្ថាប័នពាក់ព័ន្ធសំខាន់ៗអំពីគោលការណ៍ និងការអនុវត្តន៍ការគ្រប់គ្រងហានិភ័យ
- តាមដាន និងពិនិត្យឡើងវិញលើការអនុវត្តន៍ផែនការគ្រប់គ្រងហានិភ័យ និងកែលំអផែនការ តាមកាលៈទេសៈសមស្រប

## ២. រចនាសម្ព័ន្ធ និងការគ្រប់គ្រង

អង្គភាពគ្រប់គ្រងហានិភ័យស្ថិតនៅក្រោមការទទួលខុសត្រូវផ្ទាល់របស់អគ្គនាយកដ្ឋានគាំកុងត្រូល។ អង្គភាពមានបុគ្គលិកអចិន្ត្រៃយ៍ដូចមានកំណត់នៅក្នុងប្រកាសលេខ ១៩៥-អឹម អូ ស៊ី /អេស អឹម ២០១០ ចុះថ្ងៃទី ១៣ ខែកញ្ញា ២០១០។

## ៣. ផែនការយុទ្ធសាស្ត្រគ្រប់គ្រងហានិភ័យរបស់គាំកុងត្រូល

ផែនការយុទ្ធសាស្ត្រគ្រប់គ្រងហានិភ័យកំណត់អំពីបេសកកម្មរបស់អគ្គនាយកដ្ឋានគាំកុងត្រូលដែលត្រូវបំពេញក្នុងរយៈពេល ៣ឆ្នាំខាងមុខ ដោយអនុលោមតាមអាណត្តិ និងសេចក្តីណែនាំរបស់រដ្ឋាភិបាល ដើម្បីសំរេចអោយបានលទ្ធផលខាងលើ។ ផែនការត្រូវកំណត់ខ្លឹមសារយុទ្ធសាស្ត្រសំខាន់ៗ និងបញ្ជាក់ពីគោលបំណង និងទិសដៅទូលាយ ដោយរាប់ទាំងអាទិភាពមួយចំនួនទៀត។ សំរាប់ឆ្នាំ ២០១១-២០១៣

គោលបំណងសំខាន់ត្រូវបញ្ចូលការគ្រប់គ្រងហានិភ័យដែលមានលក្ខណៈច្បាស់លាស់ធ្វើជាគោលការមូលដ្ឋានសំរាប់រៀបចំរាល់សកម្មភាពរបស់អគ្គនាយកដ្ឋានកាំកុងត្រូល ។

## ៤. កម្មវិធីការងារ

កម្មវិធីការងាររបស់អង្គភាពគ្រប់គ្រងហានិភ័យត្រូវកំណត់ក្នុងផែនការប្រតិបត្តិប្រចាំឆ្នាំរបស់ខ្លួន ដោយត្រូវចងក្រងរៀបចំជារៀងរាល់ឆ្នាំស្របគ្នាជាមួយវដ្តនៃការកសាងផែនការប្រតិបត្តិ ដែលស្ថាប័នទាំងមូលត្រូវអនុវត្ត ។ ផែនការប្រតិបត្តិនេះ ត្រូវមានសង្គតិភាពជាមួយផែនការយុទ្ធសាស្ត្រគ្រប់គ្រងហានិភ័យរបស់អគ្គនាយកដ្ឋានកាំកុងត្រូល ។

ផែនការប្រតិបត្តិរបស់អង្គភាពគ្រប់គ្រងហានិភ័យនឹងត្រូវរៀបចំឡើង ក្នុងគោលបំណងដើម្បីធ្វើអោយរាល់កម្មវិធីសំខាន់ៗរបស់អគ្គនាយកដ្ឋានកាំកុងត្រូលក្នុងអំឡុងពេលបីឆ្នាំត្រូវធ្វើការវិភាគហានិភ័យ និងដើម្បីធានាយ៉ាងណាអោយការតាក់តែងកម្មវិធីថ្មីឆ្លុះបញ្ចាំងអភិក្រមផ្អែកលើហានិភ័យកាន់តែមានការសមស្របថែមទៀត ។

## ៥. វិធីសាស្ត្រវិភាគហានិភ័យ

អង្គភាពគ្រប់គ្រងហានិភ័យធ្វើការវិភាគដោយអនុវត្តតាមអភិក្រមស្តង់ដាអន្តរជាតិ ដោយប្រកាន់ខ្ជាប់គោលការណ៍ទាំង ៣ គឺ : ការវាយតម្លៃហានិភ័យ ការគ្រប់គ្រងហានិភ័យ និងការផ្សព្វផ្សាយអប់រំពីហានិភ័យ ។

ជាធម្មតា ការវិភាគហានិភ័យដែលធ្វើឡើងយដោយអង្គភាពគ្រប់គ្រងហានិភ័យគឺមានលក្ខណៈផ្អែកលើគុណភាព ។ ដោយឡែកវិធីសាស្ត្រមានការបត់បែនតាមស្ថានភាពជាក់ស្តែងរបស់ប្រទេសកម្ពុជា ។ ការវិភាគហានិភ័យផ្តោតលើបរិមាណតំរូវអោយមានវិធីសាស្ត្រស្មុគស្មាញ និងមានទិន្នន័យច្រើនបន្ថែមទៀត ដែលទិន្នន័យទាំងនេះទំនងជាមានស្រាប់រួចហើយនៅក្នុងប្រទេសកម្ពុជា ។ ( មានប្រទេសតិចតួចប៉ុណ្ណោះដែលត្រូវការប្រើប្រាស់ការវិភាគហានិភ័យផ្អែកលើបរិមាណ ដោយមានទិន្នន័យស្រាប់នេះ ហើយសុក្រិតភាពខ្ពស់ចាំបាច់តំរូវអោយមាននៅក្នុងការវិភាគនោះផងដែរ ។ )

ការវិភាគហានិភ័យអាចមានលក្ខណៈច្បាស់លាស់ ឬដោយអន្លើ ដោយផ្អែកតាមស្ថានភាពដែលត្រូវវិភាគ ។ ( ហានិភ័យអាចត្រូវបានគ្រប់គ្រងតាមរយៈវិធានការច្រើន ។ ជានិច្ចកាល កម្មវិធីអធិការកិច្ចដែលអនុវត្តដោយកាំកុងត្រូល គឺជាផ្នែកមួយនៃសកម្មភាពទាំងមូលរបស់ផ្នែកមួយនៃស្ថាប័នរដ្ឋាភិបាលក្នុងការគ្រប់គ្រងហានិភ័យ ។ ឧទាហរណ៍ ហានិភ័យដែលពាក់ព័ន្ធនឹងអាហារដែលនាំចូល អាចស្ថិតនៅក្រោមការគ្រប់គ្រងរួមគ្នារបស់ស្ថាប័នទទួលបន្ទុកត្រួតពិនិត្យព្រំដែន ការឃ្លាំពិនិត្យទីផ្សារ ការឃ្លាំពិនិត្យធាតុផ្សំតាមរោងចក្រ កម្មវិធីអប់រំ... ។ល ។

## ៦. និតិវិធីវិភាគហានិភ័យ

ជាធម្មតា ជំហានដែលអង្គភាពគ្រប់គ្រងហានិភ័យត្រូវអនុវត្តនៅក្នុងការវិភាគហានិភ័យមានដូចខាងក្រោម៖

**ជំហាន ១ : ការជ្រើសរើសប្រធានបទសំរាប់វិភាគហានិភ័យ**

*ប្រធានបទសំរាប់វិភាគហានិភ័យត្រូវជ្រើសរើសដោយប្រុងប្រយ័ត្ន ដើម្បីធានាយ៉ាងណាអោយការវិភាគអាចផ្តោតលើគ្រោះ ឬបណ្តុំគ្រោះ ដែលបានកំណត់យ៉ាងច្បាស់លាស់ ដែលពាក់ព័ន្ធនឹងទំនិញ ឬសកម្មភាពណាមួយ និងចាំបាច់ត្រូវកំណត់វិធានការគ្រប់គ្រងហានិភ័យ អោយបានសមស្របលើទំនិញ ឬសកម្មភាពទាំងនោះ ។*

*អង្គភាពគ្រប់គ្រងហានិភ័យត្រូវធ្វើការតាមប្រព័ន្ធជាក់លក្ខ័លើទំនិញ/សកម្មភាពទាំងនោះ ដែលអគ្គនាយកដ្ឋានកាំកុងត្រូលត្រូវទទួលខុសត្រូវផ្នែកបញ្ញត្តិកម្ម ក្នុងការធានាអោយមានការអនុវត្តន៍អភិក្រមផ្អែកលើហានិភ័យទូទាំងស្ថាប័ន ក្នុងពេលវេលាសមស្របណាមួយ ។*

**ជំហាន ២: ការកំណត់នាយកដ្ឋាន និងសាខាក្នុងអគ្គនាយកដ្ឋានកាំកុងត្រូល ស្ថាប័នរដ្ឋ និងភាគីផ្នែកឯកជនពាក់ព័ន្ធនានា**

*អង្គភាពគ្រប់គ្រងហានិភ័យត្រូវអនុវត្តកិច្ចការវិភាគហានិភ័យរបស់ខ្លួនក្រោមលក្ខណៈដែលមានការចូលរួម ដោយធ្វើកិច្ចសហប្រតិបត្តិការណ៍ជាមួយនាយកដ្ឋាន និងសាខាកាំកុងត្រូលពាក់ព័ន្ធ ដែលអនុវត្តវិធានការគ្រប់គ្រងហានិភ័យ ជាអាទិ៍ការងារត្រួតពិនិត្យជាដើម និងពិគ្រោះជាមួយស្ថាប័នឯកជនពាក់ព័ន្ធមួយចំនួនទៀត ។ ដូចគ្នានេះដែរ ប្រសិនបើសមស្រប អង្គភាពគ្រប់គ្រងហានិភ័យត្រូវជូនដំណឹងអំពីចេតនាក្នុងការធ្វើការវិភាគហានិភ័យរបស់ខ្លួនក្រោមប្រធានបទណាមួយដល់នាយកដ្ឋាន និងភាគីពាក់ព័ន្ធទាំងនោះ ក៏ដូចជាការជូនដំណឹងអំពី វឌ្ឍនភាពការងាររបស់ខ្លួនផងដែរ ។*

**ជំហាន ៣: ការប្រមូលទិន្នន័យបឋមដើម្បីសម្រួលដល់ការកំណត់វិសាលភាពប្រធានបទ /បញ្ហា**

*ដើម្បីជំរុញអោយការរៀបចំផែនការធ្វើការវិភាគហានិភ័យសមស្រប អង្គភាពគ្រប់គ្រងហានិភ័យត្រូវប្រមូលព័ត៌មានពាក់ពន្ធ័ ដែលមានកត់ត្រាស្រេចក្នុងស្ថិតិប្រទេសកម្ពុជា ពីបទពិសោធន៍នៅតាមបណ្តាប្រទេសដ៏ទៃទៀត ពីប្រព័ន្ធអ៊ីនធើណិត ...។ល។ ការប្រមូលទិន្នន័យដំបូងនេះត្រូវរៀបចំឡើងដោយសង្ខេប ដោយយោងហេតុផលពេលវេលា តែមិនត្រូវអោយអូសបន្លាយច្រើនសប្តាហ៍ និងមិនចាំបាច់ត្រូវប្រមូលទិន្នន័យអោយបានពេញលេញដើម្បីគាំទ្រដល់ការវិភាគហានិភ័យនោះឡើយ ។*

**ជំហាន ៤: ការរៀបចំ និងចងក្រងប្រវត្តិហានិភ័យ**

*ទិន្នន័យប្រមូលក្នុងជំហាន ៣ ចាំបាច់ត្រូវមានការត្រួតពិនិត្យ និងចងក្រងដោយសង្ខេបក្រោមលក្ខណៈជាប្រវត្តិសង្ខេបពីហានិភ័យ ។ ប្រវត្តិនេះគឺជាការវាយតំលៃហានិភ័យបឋមដែលកំណត់ពីលក្ខណៈ និងបរិបទរបស់បញ្ហាសំរាប់ផ្តល់មូលដ្ឋានក្នុងការសំរេចចិត្តថាតើការវិភាគហានិភ័យពិតជាចាំបាច់ដែរឬទេ ។ មិនគួរផ្តួចផ្តើមអោយមានការវិភាគហានិភ័យទេប្រសិនបើហានិភ័យនោះមានលក្ខណៈងាយស្រួល និងត្រូវបានគេយល់ដឹងជាស្រេច ឬប្រសិនបើគណៈគ្រប់គ្រងអាចធ្វើការសំរេចចិត្តបានសមស្របដោយមិនចាំបាច់ធ្វើការវិភាគហានិភ័យ ឬប្រសិនបើបញ្ហាមិនមានការពាក់ព័ន្ធបញ្ហាបញ្ញត្តិកម្មទេ ។*

*ក្នុងករណីមានការសំរេចចិត្តអោយបន្តអនុវត្តហើយនោះ ការវិភាគប្រវត្តិហានិភ័យលំអិតដែលជួយដល់ការសំរេចចិត្តត្រូវរៀបចំ និងចងក្រងអោយបានត្រឹមត្រូវ (សូមមើលជំហាន ៥ និង ៦ ខាងក្រោម) ។ ការចងក្រងប្រវត្តិហានិភ័យត្រូវបញ្ចូលការកំណត់អត្តសញ្ញាណ និងចរិតលក្ខណៈនៃគ្រោះ ក៏ដូចជាការវាយតម្លៃឥទ្ធិពល ឬផលប៉ះពាល់ និងការកំណត់ចរិតលក្ខណៈហានិភ័យដែរ ប៉ុន្តែជាការប្រសើរត្រូវរៀបចំឡើយក្រោមលក្ខណៈទូទៅ ។*

**ជំហាន ៥: ក៏រិតច្បាស់លាស់របស់និយមន័យនៃវិសាលភាពសិក្សា**

*ដោយផ្អែកលើប្រវត្តិហានិភ័យ ចាំបាច់ត្រូវធ្វើការសំរេចចិត្តលើបញ្ហាមួយចំនួនដើម្បីធ្វើការវិភាគដែលក្នុងនោះរួមមាន (ផលិតផល សកម្មភាព និងហានិភ័យជាក់លក្ខផ្សេងទៀត) ។*

**ជំហាន ៦: ការរៀបចំផែនការសំរាប់អនុវត្តការវិភាគហានិភ័យ**

*ការវិភាគហានិភ័យត្រូវបន្តអនុវត្តតាមផែនការដែលបានអនុម័តដោយប្រធានអង្គភាពគ្រប់គ្រងហានិភ័យ និង (ដោយឡែកសំរាប់ការសិក្សាសំខាន់) ត្រូវមានការអនុម័តដោយអគ្គនាយកកាំកុងត្រូល ដែលមានការកំណត់ច្បាស់លាស់អំពីក្របខណ្ឌពេលវេលា ប្រធានក្រុមការងារ និងធនធានផ្សេងៗដែលត្រូវប្រើ អភិក្រមដែលត្រូវអនុវត្តតាម នាយកដ្ឋាន និងសាខារបស់អគ្គនាយកដ្ឋានកាំកុងត្រូលដែលត្រូវពិគ្រោះជាមួយ ទិដ្ឋភាពព័ត៌មានសាធារណៈ (ទំនាក់ទំនងជាមួយស្ថាប័នពាក់ព័ន្ធ)... ។ល ។*

*ផែនការនេះគួរត្រូវបានពិភាក្សាជាមួយគណៈគ្រប់គ្រងរបស់នាយកដ្ឋាន និងសាខារបស់កាំកុងត្រូលទាំងអស់ដែលមានភារកិច្ចពាក់ព័ន្ធ ។*

**ជំហាន ៧: ការពិភាក្សាជាមួយស្ថាប័នពាក់ព័ន្ធ**

*សំរាប់ការវិភាគហានិភ័យដែលសំខាន់មួយចំនួន ភាគីពាក់ព័ន្ធនឹងត្រូវកំណត់ និងផ្តល់ការណែនាំអំពីផែនការនៃគំរោងរបស់ក្រុមគ្រប់គ្រងហានិភ័យ ហើយភាគីពាក់ព័ន្ធសំខាន់ទាំងអស់ត្រូវផ្តល់ការសហការណ៍ក្នុងការប្រមូលពត៌មានដែលពាក់ព័ន្ធ ។*

*ភាគីពាក់ពន្ធ័សំខាន់អាចត្រូវបញ្ចូលមិនត្រឹមតែក្រុម និងសហគ្រាសក្នុងវិស័យឯកជនប៉ុណ្ណោះទេ ប៉ុន្តែក៏បញ្ចូលទីភ្នាក់ងាររបស់រដ្ឋាភិបាលផ្សេងទៀតដែរ ។*

**ជំហាន ៨: ការប្រមូលទិន្នន័យ**

*ការវិភាគហានិភ័យផ្អែកជាសំខាន់លើទិន្នន័យប្រសើរដែលមានស្រាប់ ដែលទិន្នន័យទាំងនោះរួមមានទិន្នន័យដែលមានស្រាប់ និងទិន្នន័យមួយចំនួនទៀតដែលត្រូវប្រមូលដោយឡែកសំរាប់គោលបំណងនៃការវិភាគហានិភ័យប្រសិនបើអាចរកបាន ។ កន្លងមកនៅក្នុងការអនុវត្តន៍មានការដាក់បញ្ចូលទិន្នន័យមួយចំនួនដែលពាក់ព័ន្ធដោយផ្ទាល់ជាមួយស្ថានភាពប្រទេសកម្ពុជា ជាពិសេសពាក់ព័ន្ធសត្វានុពលមជ្ឈដ្ឋានខាងក្រៅ (សូមមើលជំហាន ១០ ខាងក្រោម) ប៉ុន្តែភាគច្រើនពឹងផ្អែកយ៉ាងខ្លាំងលើទិន្នន័យបន្ទាប់បន្សំផ្សេងទៀត ដូចជាទិន្នន័យមួយចំនួនដែលផ្តល់ដោយអង្គការអន្តរជាតិ ទីភ្នាក់ងាពាក់ព័ន្ធរបស់ប្រទេសខាងក្រៅ ឯកសារបច្ចេកទេស និងវិទ្យាសាស្ត្រ ប្រព័ន្ធអ៊ីនធើណិត និងប្រភពផ្សេងទៀតជាដើម ។*

*ទិន្នន័យចាំបាច់ភាគច្រើនសំរាប់ធ្វើការវិភាគហានិភ័យត្រូវប្រមូលនៅពេលចាប់ផ្តើមធ្វើការវិភាគ ប៉ុន្តែការប្រមូលនៅតែបន្ត ពិព្រោះមានបញ្ហាថ្មីៗអាចកើតឡើងក្នុងកំឡុងពេលនៃការវិភាគ ។*

**ជំហាន ៩: ការកំណត់អត្តសញ្ញាណគ្រោះថ្នាក់**

*រាល់គ្រោះដែលមានការពាក់ព័ន្ធជាមួយផលិតផល ឬសកម្មភាពដែលស្ថិតក្រោមការពិចារណាត្រូវកំណត់អត្តសញ្ញាណ និងពណ៌នាអោយបានច្បាស់ លាស់ ។*

**ជំហាន ១០: ការកំណត់ចរិតលក្ខណៈនៃភាពគ្រោះថ្នាក់ (ដោយរាប់ទាំងសក្តានុពលប៉ះពាល់[1])**

*រាល់គ្រោះនិមួយៗដែលបានកំណត់ត្រូវមានភ្ជាប់ជាមួយសេចក្តីបរិយាយគុណភាពអំពីលក្ខណៈ និងឥទ្ធិពលអវិជ្ជមានដែលអាចកើត ឡើង និងយន្តការដែលគ្រោះនោះស្តែងឡើង ។*

*រាល់ការវិភាគគ្រោះទាំងអស់ត្រូវកំណត់ក្រុមប្រជាជនដែលអាចរងគ្រោះ (ឧទាហរណ៍ចំពោះករណីគ្រោះថ្នាក់ម្ហូបអាហារ កំណត់ក្រុមប្រជាជនដែលអាចទទួលទានអាហារដែលមានគ្រោះថ្នាក់) ឬប្រភេទនៃការខូចខាតផ្នែកសេដ្ឋកិច្ច និងរូបវន្ត ។*

**ជំហាន ១១: ការវាយតំលៃហានិភ័យ**

*ហានិភ័យជាបរិមាណខូចខាតប្រហាក់ប្រហែលដែលអាចកើតឡើងដោយសារគ្រោះថ្នាក់ណាមួយ និងជាបណ្តុំនៃការខូចខាតធ្ងន់ធ្ងរ(ដោយផ្ទាល់ និងប្រយោល)និងភាពទំនងជាអាចកើតមាននៃគ្រោះថ្នាក់នោះ ។*

*គ្រប់ថ្នាក់ត្រូវធ្វើការវាយតម្លៃហានិភ័យតាមរយៈការវិភាគហានិភ័យ និងការវាយតំលៃលើគុណភាពដោយប្រើប្រាស់តារាងម៉ាទ្រីសវាយតំលៃដែលរៀបចំឡើងដោយអង្គភាពគ្រប់គ្រងហានិភ័យ ។ (តារាងម៉ាទ្រីសមានភ្ជាប់ - អង្គភាពគ្រប់គ្រងហានិភ័យត្រូវកំណត់ថាតើត្រូវប្រើប្រាស់មួយណា និងត្រូវដាក់ភ្ជាប់ជាឯកសារយោង ។)*

**ជំហាន ១២: ការកំណត់ជំរើសការគ្រប់គ្រងហានិភ័យដែលចង់បាន (បើចាំបាច់)**

*ការវាយតំលៃហានិភ័យជួយដល់ការវិនិច្ឆ័យថាតើហានិភ័យមានកំរិតទាបអាចទទួលយកបាន ឬត្រូវធ្វើយ៉ាងណាអោយហានិភ័យមានកំរិតទាបនឹងអាចទទួលយកបាន ដោយអនុវត្តវិធានការណ៍គ្រប់គ្រងហានិភ័យ ។ (ឯកសារភ្ជាប់ចំនួន ២ទំព័រ នឹងមានរៀបចំឡើងនៅកំឡុងពេលដំណើរបេសកកម្មទី ៥ ។)*

*នៅករណីបន្ទាប់ និងមានការកំណត់ជំរើសការគ្រប់គ្រងហានិភ័យស្របតាមលទ្ធភាពបន្ថែមទៀត ហើយវិធានការគ្រប់គ្រងហានិភ័យមួយ ឬច្រើននឹងត្រូវកំណត់បន្ថែម ដើម្បីដាក់កំហិតលើហានិភ័យអោយកាន់តែមានប្រសិទ្ធភាព និងប្រសិទ្ធផលបន្ថែមទៀតតាមដែលអាចធ្វើបានដោយពិចារណាលើកាតព្វកិច្ចរបស់ប្រទេសកម្ពុជាក្នុងនាមសមាជិករបស់អង្គការពាណិជ្ជកម្មពិភពលោក ដើម្បីសំរេចអោយបាននូវវិធាន*

[1] សក្តានុពលប៉ះពាល់ពាក់ព័ន្ធដល់ឧបទ្ទេហេតុនៃគ្រោះថ្នាក់ និងកំរិតប៉ះពាល់ដល់គ្រោះថ្នាក់មនុស្សទទួលនោះ ឧទាហរណ៍ សក្តានុពលប៉ះពាល់ទាក់ទិននឹងថ្នាំសំលាប់ សត្វល្អិតគឺជាចំនួនបរិមាណកាកសំណល់ដែលមាននៅក្នុងម្ហូបអាហារ និងចំនួនអាហារទាំងនេះនៅក្នុងរបបអាហាររបស់អ្នកទទួលទាន ជាពិសេសក្រុមងាយរងគ្រោះដូចជាទារក មនុស្សចាស់ និងមនុស្សដែលមានប្រព័ន្ធការពារខ្សោយ.. ។ល ។

*ការការពារក្រោមកំរិតសមស្របមួយដែលរារាំងតិចបំផុតដល់ពាណិជ្ជកម្មអន្តរជាតិ ។ (ឯកសារភ្ជាប់ ពន្យល់ពីផ្នែកពាក់ព័ន្ធក្នុងកិច្ចព្រមព្រៀងអនាម័យ និងភូតគាមអនាម័យ)*

**ជំហាន ១៣: សរសេរសេចក្តីព្រៀងការវិភាគហានិភ័យ**

*ជំហានបន្ទាប់ត្រូវកំណត់នៅក្នុងសេចក្តីព្រាងរបាយការណ៍វិភាគហានិភ័យ ដែលក្នុងនោះរួមមានសេចក្តីសង្ខេបអំពីទិន្នន័យដែលបានប្រើប្រាស់ជាមូលដ្ឋានសំរាប់ធ្វើការវិភាគ និងការលើកហេតុផលរបស់អង្គភាពគ្រប់គ្រងហានិភ័យក្នុងការផ្តល់អនុសាសន៏សំរាប់ចាត់វិធានការគ្រប់គ្រងហានិភ័យ ។*

**ជំហាន ១៤: ការពិភាក្សាជាមួយស្ថាប័នពាក់ព័ន្ធ**

*គួរមានការពិភាក្សាលើសេចក្តីព្រៀងរបាយការណ៍វិភាគហានិភ័យជាមួយស្ថាប័នពាក់ព័ន្ធ និងពិចារណាលើទស្សនៈរបស់ស្ថាប័នទាំងនោះអោយបានសមស្រប ។*

**ជំហាន ១៥: ការបញ្ចប់ឯកសារវិភាគហានិភ័យ**

*ត្រូវរៀបចំរបាយការណ៏បញ្ចប់ដោយបញ្ចូលអនុសាសន៏អោយបានច្បាស់លាស់ជូនដល់អគ្គនាយក ដើម្បីអនុវត្តសកម្មភាពគ្រប់គ្រងហានិភ័យអោយបានសមស្រប ក្រោមអាណត្តិរបស់អគ្គនាយកដ្ឋានកាំកុងត្រូល ។*

**ជំហាន ១៦: ការផ្សព្វផ្សាយអំពីហានិភ័យ តាមការចាំបាច់**

*អង្គភាពគ្រប់គ្រងហានិភ័យ និងនាយកដ្ឋាន និងសាខាទាំងអស់របស់អគ្គនាយកដ្ឋានកាំកុងត្រូលត្រូវទទួលខុសត្រូវរួមគ្នាលើការផ្សព្វផ្សាយហានិភ័យដែលបានវាយតំលៃ និងកម្មវិធីគ្រប់គ្រងលើហានិភ័យ ដើម្បីគ្រប់គ្រងហានិភ័យទាំងនោះ ជូនដល់ស្ថាប័នពាក់ព័ន្ធ ។*

# លំហូរនិតិវិធីសំរាប់វិភាគហានិភ័យ



## ៧. កិច្ចសហប្រតិបត្តិការណ៍ជាមួយអគ្គនាយកដ្ឋានកាំកុងត្រូល

អនុលោមតាមមាត្រា ៣ របស់ប្រកាសរបស់ក្រសួងពាណិជ្ជកម្មលេខ ១៩៥ អឹម អូ ស៊ី /អេស អឹម ២០១០ ប្រធានកម្មវិធី ( ប្រធាននាយកដ្ឋាន និងប្រធានសាខាទាំងអស់របស់អគ្គនាយកដ្ឋានកាំកុងត្រូលត្រូវសហការ និងគាំទ្រដល់អង្គភាពគ្រប់គ្រងហានិភ័យ តាមរយៈការផ្តល់ប្រឹក្សា និងព័ត៌មានដែលពាក់ពន្ធ័លើសកម្មភាពកម្មវិធីអោយទាន់ពេលវេលា ។

អង្គភាពគ្រប់គ្រងហានិភ័យត្រូវជួយប្រធានគ្រប់គ្រងកម្មវិធី នៅក្នុងការអនុវត្តន៍អភិក្រមផ្អែកលើហានិភ័យដោយផ្អែកលើការវិភាគហានិភ័យ ។

## ៨. កិច្ចសហប្រតិបត្តិការណ៍ជាមួយក្រសួងពាក់ព័ន្ធ

អង្គភាពគ្រប់គ្រងហានិភ័យត្រូវធ្វើការងារជាមួយក្រសួងពាក់ព័ន្ធផ្សេងទៀត ជាពិសេសស្វែងរកការជួយគាំទ្រក្នុងការប្រមូលទិន្នន័យពាក់ពន្ធ័ និងសហការណ៏លើការវិភាគហានិភ័យ ក្នុងករណីជំរើសគ្រប់គ្រងហានិភ័យមានការពាក់ព័ន្ធជាមួយការទទួលខុសត្រូវរបស់ស្ថាប័នទាំងនោះបន្ថែមលើការការទទួលខុសត្រូវរបស់កាំកុងត្រូល ។

## ៩. ការរៀបចំរបាយការណ៍

អង្គភាពគ្រប់គ្រងហានិភ័យត្រូវអនុវត្តតាមនិតិវិធីស្តង់ដាសំរាប់ផ្សព្វផ្សាយលទ្ធផលវិភាគហានិភ័យ និងរាយការណ៏លើសកម្មភាពរបស់ខ្លួន ។

**ឧបសម្ព័ន្ធ-១៖**

## តារាងម៉ាទ្រីកនៃការវាយតម្លៃហានិភ័យ

| | | Severity | | | |
|---|---|---|---|---|---|
| | | Low (L) | Moderate (M) | High (H) | Extreme (E) |
| Likelihood (Probability) | E | **M** | **H** | **E** | **E** |
| | H | **L** | **M** | **H** | **E** |
| | M | **VL** | **L** | **M** | **H** |
| | L | **VL** | **VL** | **L** | **M** |